# ពរជ័យ មកពី ប្លេះស៊ី

ខ្ញុំរស់នៅប្រទេសឥណ្ឌាជាមួយគ្រួសារខ្ញុំ ។ ខ្ញុំត្រូវដាក់ផែនការសកម្មភាពពិសេសមួយ សម្រាប់សាលារៀនរបស់ខ្ញុំ ហើយចែកចាយដំណឹងល្អជាមួយនឹងមិត្តភក្តិរបស់ខ្ញុំ !

ជំរាបសួរ ! ខ្ញុំឈ្មោះ ប្លេះស៊ី ។



## ១

**អ្នកផ្សព្វផ្សាយសាសនាវ័យក្មេង**

*អ្នកដឹកនាំថ្នាក់បឋមសិក្សារបស់ខ្ញុំ បង្រៀនថាយើងគួរធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។ ជួនកាលខ្ញុំអញ្ជើញមិត្តភក្តិរបស់ខ្ញុំឲ្យទៅព្រះវិហារ ។ ភាគច្រើនពួកគេបដិសេធខ្ញុំ ។ ខ្ញុំគិតថាប្រហែលជាខ្ញុំនៅក្មេងពេកដើម្បីធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។*

## ២

**ការអញ្ជើញជាគ្រួសារ**

*ក្រោយមក នៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ប៉ាបានសំណូមពរដល់គ្រួសាររបស់យើងឲ្យនាំមនុស្សម្នាក់មកព្រះវិហាររៀងរាល់ខែ ។ ខ្ញុំចង់ធ្វើវា ប៉ុន្តែវាពិបាកណាស់ ! ខ្ញុំបានសូមជំនួយពីប៉ា ។ គាត់បានប្រាប់ថា ឲ្យខ្ញុំអធិស្ឋាន ។ ដូច្នោះខ្ញុំក៏បានអធិស្ឋាន ។*

## ៣

**យោបល់**

*ថ្ងៃស្អែកឡើងនៅឯសាលារៀន នាយកសាលាបានសួរយោបល់សម្រាប់សកម្មភាពបុណ្យគ្រីស្ទម៉ាស់នៅសាលា ។ ខ្ញុំមានគំនិតអស្ចារ្យមួយ ! ខ្ញុំបានប្រាប់គាត់ថា កុមារនៅក្នុងថ្នាក់បឋមសិក្សាទាំងអស់អាចមកលេងព្រះវិហាររបស់ខ្ញុំ ។ គាត់បានទូរសព្ទទៅឪពុកម្ដាយរបស់ខ្ញុំ ហើយពួកគាត់បាននិយាយជាមួយប៊ីស្សពដើម្បីដាក់ផែនការពីសកម្មភាពនោះ ។ ពួកអ្នកដឹកនាំថ្នាក់អង្គការបឋមសិក្សា និង អ្នកផ្សព្វផ្សាយសាសនាបានជួយកិច្ចការនោះផងដែរ ។*



## ៤

**ថ្ងៃដ៏រំភើប**

*មិនយូរប៉ុន្មានថ្ងៃនោះបានមកដល់ ។ ខ្ញុំមានអារម្មណ៍ភិតភ័យ និង រំភើបក្នុងពេលជាមួយគ្នា ។ នៅពេលប៉ាបានយកខ្ញុំទៅសាលារៀន ខ្ញុំបានឃើញពួកគេនៅទីនោះ ហើយត្រៀមខ្លួនរួចជាស្រេច ។ មានសិស្ស និង គ្រូបង្រៀនជិត ៥០០ នាក់បានមក !*



## ៥

**ទាំងអស់គ្នានៅព្រះវិហារ**

*នៅព្រះវិហារយើងបានមើលវីដេអូមួយអំពីការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ។ យុវមជ្ឈិមវ័យ និង អ្នកផ្សព្វផ្សាយសាសនាបានច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ ។ ប៊ីស្សព និង ប៉ារបស់ខ្ញុំបាននិយាយអំពីរបៀបដែលព្រះយេស៊ូវស្រឡាញ់ក្មេងតូចៗ និង អំពីសេចក្ដីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក ។ ខ្ញុំបាននិយាយអំពីបុណ្យគ្រីស្ទម៉ាស់ ។ អ្នកទាំងអស់គ្នាមានគ្រាដ៏រីករាយមួយ ! នាយកសាលា និង គ្រូបង្រៀនរបស់ខ្ញុំបានសួរសំណួរនានាដល់អ្នកផ្សព្វផ្សាយសាសនា ។*

### យោបល់របស់ប្លេះស៊ី ដើម្បីឈរយ៉ាងរឹងប៉ឹង

- អធិស្ឋានសូមជំនួយ ។
- អញ្ជើញមនុស្សឲ្យមកព្រះវិហារ ទោះបីអ្នកគិតថាពួកគេបដិសេធអ្នកក៏ដោយ ។
- ចូរចាំថាព្រះវរបិតាសួគ៌នឹងជួយអ្នក ។